## រឿងទី១០៖ យ៉ូណាស

**ខគម្ពីរ៖ យ៉ូណាស៤៖១១**

រីឯយើងវិញ តើមិនឲ្យយើងអាណិតក្រុងនីនីវេមហានគរនេះដូចម្ដេចបាន ដ្បិតមានប្រជាជនជាងដប់ពីរម៉ឺននាក់ ដែលមិនទាន់ដឹងខុសត្រូវ ព្រមទាំងមានហ្វូងសត្វច្រើនឥតគណនារស់នៅក្នុងក្រុងនេះទៀតផង៕

កាលពីយូរលង់ណាស់មកហើយ មានបុរសម្នាក់ឈ្មោះយ៉ូណាស់ គាត់រស់នៅក្នុងស្រុកអ៊ីស្រាអ៊ែល។ គាត់ គឺជាអ្នកដែលប្រកាសព្រះបន្ទូលព្រះជាម្ចាស់។

ថ្ងៃមួយ ព្រះជាម្ចាស់យាងមកជួបយ៉ូណាស់ ហើយមានបន្ទូលទៅគាត់ថា៖ «យ៉ូណាស់អើយ ចូរឯងធ្វើដំណើរទៅទីក្រុងនីនីវេ ប្រាប់ពួកគេឱ្យឈប់ធ្វើការអាក្រក់ទៅ»។

ទីក្រុងនីនីវេ គឺជាទីក្រុងដ៏ធំបំផុតមួយ។ ជាទីក្រុងដែលសម្បូរទៅដោយអ្នកមានអំណាច និងអ្នកមាន។

ប៉ុន្តែ អ្នកក្រុងនីនីវេទាំងនោះ មិនស្រឡាញ់អ្នកជិតខាង អាត្មានិយម រស់នៅសម្រាប់តែខ្លួនឯង។ ដូច្នេះហើយ ទើបយ៉ូណាសមិនចង់ធ្វើតាមការបង្គាប់របស់ព្រះជាម្ចាស់ទេ។

យ៉ូណាស មិនទៅនីនីវេតាមបង្គាប់របស់ព្រះជាម្ចាស់ទេ គាត់បានជិះទូកទៅតើស៊ីសវិញ មិនទៅនីនីវេទេ។

ទូកកំពុងតែបើកទៅមុខសុខៗ ស្រាប់តែភ្លាមនោះ ក៏មានខ្យល់ព្យុះបក់មកយ៉ាងខ្លាំងមកលើទូក!

មនុស្សនៅក្នុងទូក បានធ្វើការចាប់ឆ្នោតរើសអ្នកដែលធ្វើឱ្យមានខ្យល់ព្យុះនេះ។ អ្នកដែលត្រូវគេចាប់ឆ្នោតបាននោះគឺយ៉ូណាស។

មនុស្សទាំងអស់ បានបោះយ៉ូណាសចេញពីទូក ដើម្បីធ្វើឱ្យព្យុះស្ងប់។ ជារឿងគួរឱ្យភ្ញាក់ផ្អើល ពេលបោះយ៉ូណាសភ្លាម ខ្យល់ក៏ស្ងប់ រលកក៏ស្ងប់។

មានត្រីដ៏ធំមួយបានលេចមកលេបយ៉ូណាសដែលបានធ្លាក់ចូលទៅក្នុងទឹកសមុទ្រចូលទៅក្នុងពោះ។

ត្រីនេះ គឺជាត្រីដែលព្រះជាម្ចាស់បញ្ជូនមក។ យ៉ូណាសបាន អធិស្ឋាននៅក្នុងពោះត្រីអស់រយៈពេលបីថ្ងៃ។

ព្រះជាម្ចាស់បានឆ្លើយតបការអធិស្ឋានរបស់យ៉ូណាស។ នៅថ្ងៃទីបីនោះ ត្រីបានខ្ជាក់យ៉ូណាសនៅលើដីគោកមួយ។

ទីបំផុត យ៉ូណាសក៏បានចេញពីក្នុងពោះត្រីមក។ យ៉ូណាសបានចេញទៅទីក្រុងនីនីវេដើម្បីប្រកាសព្រះបន្ទូលតាមការបង្គាប់របស់ព្រះជាម្ចាស់។

យ៉ូណាសបានដើរពាសស្រុកប្រកាសពីព្រះបន្ទូលយ៉ាងខ្លាំងៗពេញមួយថ្ងៃ។ អ្នកទីក្រុងនីនីវេ បានឮអ្វីដែលយ៉ូណាសប្រកាសហើយ មានការភ័យខ្លាចជាខ្លាំង។

ដូច្នេះ មនុស្សទូទាំងក្រុង មិនបរិភោគអ្វីទាំងអស់ ហើយអធិស្ឋានទៅព្រះជាម្ចាស់។

ព្រះជាម្ចាស់ទតឃើញថាជំនឿរបស់ពួកគេជាជំនឿពិតប្រាកដ ដូច្នេះ ទ្រង់ក៏លើកលែងទោសដល់ពួកគេ។

ហើយប្រជាជននីនីវេ និងទីក្រុងនីនីវេ ក៏មិនត្រូវបានបំផ្លាញដែរ។





**សកម្មភាពទី១** សូមឆ្លើយសំណួរខាងក្រោម។

a. តើព្រះជាម្ចាស់បានចាត់លោកយ៉ូណាសឱ្យទៅក្រុងណា? ប៉ុន្តែលោកយ៉ូណាសមិនបានស្ដាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ តើលោកបានរត់គេចទៅឯណា?

---

b. ទីបំផុត លោកយ៉ូណាសបានទៅដល់ក្រុងនីនីវេ ហើយបានប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងខ្លាំងក្លា។ តើប្រជាជននីនីវេបានធ្វើអ្វីខ្លះ នៅពេលដែលពួកគេបានឮការប្រកាសរបស់លោកយ៉ូណាស?

---

c. សូមអានយ៉ូណាស៣៖១-១០ រួចឆ្លើយសំណួរ។ តើព្រះជាម្ចាស់បានធ្វើអ្វីខ្លះចំពោះប្រជាជននីនីវេ ដែលបានប្រែចិត្តបន្ទាប់ពីបានឮការប្រកាសរបស់លោ កយ៉ូណាស?

---

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (យ៉ូណាស ៤:១១)

រីឯយើងវិញ តើមិនឲ្យយើងអាណិតក្រុងនីនីវេមហានគរនេះដូចម្ដេចបាន ដ្បិតមានប្រជាជនជាងដប់ពីរម៉ឺននាក់ ដែលមិនទាន់ដឹងខុសត្រូវ ព្រមទាំងមានហ្វូងសត្វច្រើនឥតគណនារស់នៅក្នុងក្រុងនេះទៀតផង»។



## សកម្មភាពទី២

សូមកាត់រូបលោកយ៉ូណាស និងត្រីធំតាមបន្ទាត់ចុចៗ រួចព្យួររូបលោកយ៉ូណាស ដូចរូបភាពគំរូដែលធ្វើរួចរាល់។

សម្ភារៈ៖ កន្ត្រៃ, ប្រដាប់ខ្ទាស់, អំបោះ, ស្កុត



រូបភាពរួចរាល់



KIDS GOD WORSHIP
www.kidsworship.kr

Selah
Ministerio de Publicación Cristiano

ឈ្មោះ: